ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

លេខ :...016.........សជណ.កសស.នក

ក្រុងព្រះសីហនុ.ថ្ងៃទី 11 ខែ ឧសភា ឆ្នាំ ២០០៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការកំណត់ជំរៅទឹកនាវាពាណិជ្ជកម្មជាតិ និងអន្តរជាតិ ដែលចូល_ចេញ នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ
## ប្រធានអគ្គនាយក

សូមជំរាបជូនដំណឹងដល់អស់លោក លោកស្រី ជាម្ចាស់ក្រុមហ៊ុននាវាពាណិជ្ជកម្ម និង អន្តរជាតិទាំងអស់ មេត្តាជ្រាបថា ការសាងសង់ផែចំណតនាវាកុងតែន័រ (Container Terminal) បន្ថែម 400 ម៉ែត្រ និងការបូមស្តារប្រឡាយនាវាចូល-ចេញ បានរួចរាល់ហើយដើម្បីដាក់ជូនគ្រប់ក្រុមហ៊ុននាវា និង អ្នកប្រើប្រាស់ផែ (Port Users) ឱ្យគ្រប់គ្រាន់បំរើសេវារហ័សទាន់ចិត្តប្រកបដោយសុវត្ថិភាពខ្ពស់តាមសំណូមពរអស់លោក លោកស្រី ជាអ្នកប្រើប្រាស់កំពង់ផែដូចនេះ ខ្ញុំសូមប្រកាសកំណត់លក្ខណៈបច្ចេកទេសជាផ្លូវការសំរាប់នាវាគ្រប់ប្រភេទដូចបានជំរាបជូនជាបន្តបន្ទាប់ដូចខាងក្រោមនេះ :

## I- ព័ត៌មានទូទៅ:

| | | |
|---|---|---|
| ១- | អតិបរិមាជំរៅទឹកផ្នែកទិសឧត្តរ (North) | :10ម៉ែត្រ Anchorage |
| ២- | ស្ថានីយ៍កណ្តូចារ | :Latitude 10°39'5N<br>:Longitude 103°29'OE |
| ៣- | ជំនួយកណ្តូចារ (Pilot) | :ធ្វើការ 24 ម៉ោង លើ 24ម៉ោង (ប៉ុន្តែបើនាវាតម្រូវការចេញពេលយប់ត្រូវដាក់ពាក្យសុំចេញនាវាពេលថ្ងៃទុកជាមុន) ។ |
| ៤- | វិទ្យុទាក់ទង (Radio Frequency) | :សុំប្រើ Frequency 156-80$^{C}$16 ទាក់ទងផ្ទាល់ជាមួយ Sihanoukville Port Control ឬ កាំសាប Ship Agent ។ |
| ៥- | ភ្នាក់ងារនាវាចរ | :Ship's Agent សាខាកាំសាបក្រុងព្រះសីហនុ ។ |

II- **កំណត់ជំរៅទឹកនាវាមានពីខ្សែរសខ្វាត់:**

១- ចំពោះនាវាមានជំរៅទឹក 8.1m ត្រូវបានចូល-ចេញផែគ្រប់ពេល (Anytime)

២- ចំពោះនាវាមានជំរៅទឹកត្រឹម 8.3m ត្រូវធ្វើការរង់ចាំចូលចតឬចេញពីផែនៅពេលទឹកជោរ (HWL)

ករណីមានខ្យល់ខ្លាំងចាប់ពីល្បឿន 19 Knot ឡើងទៅនាវាគ្រប់ប្រភេទត្រូវរង់ចាំល្បឿនខ្យល់ចុះខ្សោយដល់ 18Knot ចុះក្រោមទើបធ្វើចលនានាវាជាធម្មតា ។

III- **អាស័យដ្ឋានទំនាក់ទំនង:**

១- កំពង់ផែស្វយ័តក្រុងព្រះសីហនុ វិថីផែ សង្កាត់ ៣ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ

ទូរស័ព្ទ (855)16345228, (855)34390456, ទូរស័ព្ទ (855)34933693/917 ។

Website: www.pas.gov.kh, E-mail: pas@camintel.com, paspmu@camintel.com,

២- សាខាកាំសាប(ភ្នាក់ងារនាវាចរ) Kamsab Branch Sihanoukville

- **Mr. Nhean Sokol** (Manager of Sihanoukville Branch)
  h/p(855)12900276 E-mail: kamsabbranch@camintel.com, sihbranch@kamsab.comkh,

- **Mr. Ros Surey** (Asst. Manager) h/p(855)12939752
  E-mail: sihoprtn@kamsb.comkh,

- **Mr. Yin Rin** (Chief Boarding Agents) h/p(855)12939196
  E-mail: sihshpng@kamsab.comkh and
  012 939 196@mobitel.comkh,

**កំណត់ចំណាំ:**

សូមបញ្ជាក់ផងដែរថាចំណុចបោះយុថ្កានាវាផ្នែកទិសទក្សិណ (South Anchorage) និង ចំណុចបោះយុថ្កានាវាប្រេងផ្នែកទិសឧត្តរឈាងខាងជើង (W.N Anchorage) នៅរក្សាទុកគ្រប់គ្រងប្រើប្រាស់តាមបច្ចេក-ទេសដដែល និងប្រក្រតី ។

អាស្រ័យដូចបានប្រកាសជូនដំណឹងខាងលើនេះ ខ្ញុំសូមសង្ឃឹមថាលោក លោកស្រីជួយគាំទ្រ និង ប្រើប្រាស់កំពង់ផែទទួលបានជោគជ័យលើការងារពាណិជ្ជកម្ម អាជីវកម្ម របស់លោក លោកស្រីជាពុំខាន ឡើយ ។

សូមលោក លោកស្រីទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំបាទ ។

**ប្រធានអគ្គនាយក**

**លូ_គីមឈន់**

**ចំលងជូន:**

- **នាយកដ្ឋានពាក់ព័ន្ធ**
  “ ដើម្បីមុខការ”
- **ឯកសារកាលប្បវត្ត**